# មជ្ឈមណ្ឌលឯកសារកម្ពុជា

**បាឋកថាស្តីអំពី**

**«ការរួមចំណែកទៅលើអធិបតេយ្យភាពក្នុងដំណើរការកសាងសន្តិភាព»**

ដោយ John Ciorciari

**ថ្ងៃសុក្រ ទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៦ វេលាម៉ោង ៥:០០ ល្ងាច**

ទីតាំង: វិចិត្រសាលសិល្បៈសហសម័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

អគារ H វិទ្យាស្ថានជាតិអប់រំ

ភាសា: អង់គ្លេស

វិចិត្រសាលសិល្បៈសហសម័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា សូមជូនដំណឹងថា វិចិត្រសាលនឹងរៀបចំ បាឋកថាទីដប់ប្រាំមួយ ស្តីអំពី «**ការរួមចំណែកទៅលើអធិបតេយ្យភាពក្នុងដំណើរការកសាងសន្តិភាព**» ដោយ John Ciorciari។ សិស្ស និស្សិត គរុសិស្ស និងសាធារណជន អាចចូលរួម ដោយសេរី។

ជារើយៗ សហគមន៍អន្តរជាតិដែលចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងកសាងសន្តិភាពបានចូលរួមចំណែកក្នុងការទទួលខុសត្រូវទៅលើមុខងារចម្បងផ្សេងៗទាក់ទងទៅនឹងអធិបតេយ្យភាព នៅពេលដែលរដ្ឋាភិបាលប្រទេសមួយមិនអាចអនុវត្តប្រកបដោយប្រសិទ្ធភាព។ រវាងរដ្ឋបាលអន្តរជាតិ និងជំនួយផ្នែកហិរញ្ញវត្ថុ ឬបច្ចេកទេស ការរួមចំណែកផ្នែកអធិបតេយ្យភាពភាគច្រើនធ្វើឡើងក្នុងគោលបំណងគាំទ្រដល់ការពង្រឹងសមត្ថភាពក្នុងស្រុក រក្សាភាពជាម្ចាស់ស្រុក និងធម្មានុរូបភាព ព្រមទាំងការពង្រឹងស្ថាប័នរដ្ឋ។ ប៉ុន្តែ នៅក្រោមជំនួយបែបនេះ បញ្ហាមួយចំនួនក៏អាចកើតមានឡើងដែរ ដូចជាភាពច្រំដែល ភាពច្របូកច្របល់ គម្លាតនៃភាពជាម្ចាស់ និងជម្លោះនយោបាយរវាងអាជ្ញាធរអន្តរជាតិ និងរដ្ឋម្ចាស់ស្រុក។ ជោគជ័យភាគច្រើនពឹងផ្អែកទៅលើការរក្សាលំនឹងផ្នែកនយោបាយ ដែលជារើយៗមានភាពផុយស្រួយ និងឆាប់សាបរលាប។ ជាទូទៅ រដ្ឋាភិបាលនៃប្រទេសមួយមានការស្ទាក់ស្ទើរក្នុងការបែករំលែកអំណាចផ្នែកអធិបតេយ្យភាព។ រីឯ សហគមន៍អន្តរជាតិវិញមិនអាច និងមិនមានបំណងទទួលកាន់កាប់មុខងារផ្នែកអធិបតេយ្យប្រកបដោយប្រសិទ្ធភាពនោះឡើយ។ កត្តានេះបង្កឲ្យមានភាពលំអៀង និងឈានទៅដល់ការប្រឆាំងនឹងការតាក់តែង និងការអនុវត្តឲ្យមានប្រសិទ្ធភាពទៅលើកិច្ចព្រមព្រៀងស្តីអំពីការរួមចំណែកទៅលើអធិបតេយ្យភាព។ ដើម្បីសម្រេចបានជោគជ័យសម្រាប់ភាគីទាំងសង តោងតម្រូវឲ្យអាជ្ញាធរក្នុងស្រុកប្តេជ្ញាក្នុងការកែទម្រង់ និងភាគីអន្តរជាតិមានជំហរដឹកនាំរឹងមាំ ព្រមទាំងការបំពេញតម្រូវការសមរម្យរវាងការផ្តល់ជំនួយរបស់ភាគីអន្តរជាតិ និងតម្រូវការរបស់រដ្ឋម្ចាស់ស្រុក។ ករណីសិក្សាពីប្រទេសលីបេរីយ៉ា ប្រទេសកម្ពុជា និងប្រទេសទីម័រខាងកើត បានបង្ហាញឲ្យឃើញអំពីសក្តានុពលភាពវិជ្ជមាននៅក្នុងដំណើរការនេះ និងបញ្ហាប្រឈមដែលបានកើតឡើងក្នុងពេលអនុវត្តជាក់ស្តែង។

**John Ciorciari** (JD, Harvard; DPhil, Oxford) គឺជាសាស្ត្រាចារ្យរង និងនាយកនៃមជ្ឈមណ្ឌលនយោបាយអន្តរជាតិនៃវិទ្យាស្ថាននយោបាយសាធារណ Gerald R. Ford នៃសាកលវិទ្យាល័យ Michigan។ ទន្ទឹមនឹងនេះ លោក ជាទីប្រឹក្សាជាន់ខ្ពស់ផ្នែកច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ លោក ជាអ្នកនិពន្ធសៀវភៅ The Limits of Alignment: Southeast Asia and the Great Powers since 1975 (2010) និងជាសហអ្នកនិពន្ធសៀវភៅជាមួយ Anne Heindel ដែលមានចំណងជើងថា Hybrid Justice: The Extraordinary Chambers in the Courts of Cambodia (2014)។ ការសិក្សាស្រាវជ្រាវរបស់លោកស្តីអំពីការរួមចំណែកទៅលើអធិបតេយ្យភាពទទួលបានការឧបត្ថម្ភពី the Carnegie Corporation of New York។

## សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖

ការចងចាំ និងយុត្តិធម៌

«...សង្គមមួយមិនអាចស្គាល់ខ្លួនឯងបាន ប្រសិនបើសង្គមនោះមិនមានការចងចាំដ៏ត្រឹមត្រូវអំពីប្រវត្តិសាស្ត្ររបស់ខ្លួន។»

ម៉ែន ពិចិត្រ

វិចិត្រសាលសិល្បៈសហសម័យ

មជ្ឈមណ្ឌលឯកសារកម្ពុជា

ទូរសព្ទ +៨៥៥ ២៣ ២១៤ ០០៩

អ៊ីម៉ែល truthmpechet@dccam.org

គេហទំព័រ www.dccam.org